ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ១៣៨ ឧរថ.មមជ.ប្រក

# ប្រកាស
# ស្ដីពី
# នីតិវិធី និងបែបបទនៃការស្នើសុំអាជ្ញាប័ណ្ណ ផលិត និងជួសជុលឧបករណ៍មាត្រាសាស្ត្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បកចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានឃើញប្រកាសលេខ ៧៣៩ ឧរថ.មមជ.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ ស្ដីពីសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានឃើញប្រកាសលេខ ៨៦១ ឧរថ.បល.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
- បានឃើញប្រកាសលេខ ៨៥៩ឧរថ.ម.ម.ជ.ប្រក ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១១ ស្ដីពីសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រ


៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

- បានឃើញប្រកាសលេខ ៨៦០ ឧរថ.ម.ម.ជ.ប្រក ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីនីតិវិធីនៃការដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រ
- បានឃើញសេចក្តីជូនដំណឹងលេខ ១៣២៤ឧរថ.ម.ម.ជ.សជណ ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការអនុវត្តច្បាប់មាត្រាសាស្ត្រកម្ពុជា
- ពិនិត្យតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១** : ប្រកាសនេះ មានគោលដៅកំណត់យន្តការ និង វិធានគ្រប់គ្រងការផលិត និង ជួសជុលឧបករណ៍មាត្រាសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា និង ក្នុងគោលបំណងៈ

- ធានាឲ្យការធ្វើពាណិជ្ជកម្មមានភាពយុត្តិធម៌និងត្រឹមត្រូវ
- បង្កឲ្យការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ មានភាពត្រឹមត្រូវសុចរិត
- ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និង អ្នកប្រើប្រាស់ ផលិតផលទំនិញ និង សេវាកម្ម
- ធានាធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពទំនិញ ផលិតផល សេវាកម្ម និង គ្រប់គ្រង
- កំណត់អត្តសញ្ញាណ និង លុបបំបាត់របាំងបច្ចេកទេស ដើម្បីឲ្យមានសុខដុមនីយកម្ម ក្នុងសកម្មភាពពាណិជ្ជកម្ម លើវិស័យនីត្យានុកូលមាត្រាសាស្ត្រ
- ធ្វើឲ្យមានជំនឿ និង ទំនុកចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រក្នុងសកម្មភាពពាណិជ្ជកម្ម និង វិស័យផ្សេងៗទៀត ដើម្បីសុខភាព សុវត្ថិភាព និង បរិស្ថាន
- សម្រួលការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកទេសដើម្បីភាពរីកចម្រើននៃសេដ្ឋកិច្ច។

**ប្រការ ២** : វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះ :

**មាត្រាសាស្ត្រ** សំដៅដល់ វិទ្យាសាស្ត្រ និង ការគ្រប់គ្រងទម្ងន់និងរង្វាស់រង្វាល់។

**នាយកដ្ឋានទទួលបន្ទុក** សំដៅដល់ នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ។

**ឧបករណ៍មាត្រាសាស្ត្រ** សំដៅដល់ ឧបករណ៍ទម្ងន់ និង រង្វាស់រង្វាល់ដែលបំរើឲ្យវិស័យមាត្រាសាស្ត្រ។

**បរិក្ខារ** សំដៅដល់ សម្ភារៈសម្រាប់ថ្លឹង ឬវាស់វាល់ ឬគ្រឿងផ្សំសម្រាប់ឧបករណ៍មាត្រាសាស្ត្រ។

**ឧបករណ៍វាស់វាល់** សំដៅដល់ ឧបករណ៍មាត្រាសាស្ត្រសម្រាប់ប្រើប្រាស់រកបរិមាណនៃប្រព័ន្ធឯកតាចំណុះវត្ថុរាវ ប្រវែង សម្ពាធ សំឡេង ពន្លឺ ថាមពល។ល។

**បុគ្គល** សំដៅដល់ នីតិបុគ្គល ឬ រូបវន្តបុគ្គល។

**មន្ត្រីត្រួតពិនិត្យ** សំដៅដល់មន្ត្រីមានសមត្ថកិច្ចរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**ការផលិត** សំដៅដល់ ការកែច្នៃវត្ថុធាតុដើមឲ្យទៅជាផលិតផលសម្រេចដោយប្រើប្រាស់បច្ចេកវិជ្ជានៅក្នុងរោងចក្រ ឬ សិប្បកម្ម។

**ការជួសជុល** សំដៅដល់ ការធ្វើឲ្យដូចដើមវិញនូវឧបករណ៍មាត្រាសាស្ត្រដែលបានខូចខាតទ្រង់ទ្រាយដើម មិនដំណើរការឬ ធ្វើឲ្យថ្មីនូវឧបករណ៍ចាស់។

**ពាក្យស្នើសុំ** សំដៅដល់ ពាក្យស្នើសុំអាជ្ញាប័ណ្ណផលិត ឬ ជួសជុល ដែលជាសំណើផ្លូវការជាលាយលក្ខណ៍អក្សរបញ្ជូនមកនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដោយផ្ទាល់ ឬ តាមរយៈសាខាមជ្ឈមណ្ឌលមាត្រាសាស្ត្រ (ម.ម.ជ) រាជធានី-ខេត្ត។ ពាក្យស្នើសុំរួមមាន ឯកសារតម្រូវទាំងអស់ដែលមានចែងសម្រាប់ប្រភេទនៃប្រកាសអាជ្ញាប័ណ្ណផលិត និង ជួសជុល ឧបករណ៍មាត្រាសាស្ត្រ។

**អាជ្ញាប័ណ្ណ** សំដៅដល់ អាជ្ញាប័ណ្ណផលិត ឬ អាជ្ញាប័ណ្ណជួសជុល។

**អាជ្ញាប័ណ្ណផលិត** សំដៅដល់ ការទទួលស្គាល់ជាលាយលក្ខណ៍អក្សរពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិថា ម្ចាស់រោងចក្រសិប្បកម្មបានទទួលសិទ្ធិស្របច្បាប់ក្នុងកិច្ចដំណើរការផលិតឧបករណ៍មាត្រា-សាស្ត្រ។

**អាជ្ញាប័ណ្ណជួសជុល** សំដៅដល់ ការទទួលស្គាល់ជាលាយលក្ខណ៍អក្សរពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិថា ម្ចាស់រោងចក្រ សិប្បកម្មបានទទួលសិទ្ធិស្របច្បាប់ក្នុងដំណើរការជួសជុលឧបករណ៍មាត្រា-សាស្ត្រ។

**ឯកសារតម្រូវ** សំដៅដល់ ឯកសារតម្រូវឲ្យមានភាពអនុលោមដែលកំណត់ដោយ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដើម្បីទទួលបានការអនុញ្ញាតណាមួយយោងតាមប្រកាសនេះ។

**អនុម័តគំរូ** សំដៅដល់ការអនុម័តលើគំរូជាក់លាក់ណាមួយនៃឧបករណ៍មាត្រាសាស្ត្រសម្រាប់ដាក់ឲ្យប្រើប្រាស់ បន្ទាប់ពីបានសាកល្បងឧបករណ៍មួយ ឬ ច្រើនស្របតាមការតម្រូវដែលបានកំណត់។

**គំនូសបច្ចេកទេស** សំដៅដល់ គំនូសបង្ហាញនៃឧបករណ៍មាត្រាសាស្ត្រជាបីគំហើញ បញ្ឈរ ផ្តេក និងពុះចំពីលើដោយមានបញ្ជាក់ពីទំហំ រូបរាង ខ្នាតរបស់ឧបករណ៍មាត្រាសាស្ត្រដែលស្នើសុំផលិត ឬ ជួសជុលទៅតាមបច្ចេកទេសដែលបានកំណត់ហើយគំនូសនេះត្រូវគូស និង បញ្ជាក់ដោយអ្នកបច្ចេកទេសដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬ សញ្ញាបត្រដែលមានតម្លៃស្មើ ពិសេសពាក់ព័ន្ធនឹងជំនាញមេកានិច។

**គំរូឧបករណ៍** សំដៅដល់ សំណាកគំរូឧបករណ៍មាត្រាសាស្ត្រ ដែលមានរូបរាង ទ្រង់ទ្រាយ ទំហំ ខ្នាត និងយកមកតំកល់ទុកជាគំរូក្រោយការផលិត។

**ប្រកាសអនុញ្ញាតបង្កើតរោងចក្រនិងសិប្បកម្ម** សំដៅដល់ ការអនុញ្ញាតជាលាយលក្ខណ៍អក្សរមានសុពលភាពអចិន្ត្រៃយ៍ដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សម្រាប់បង្កើតរោងចក្រថ្មី ឬ សិប្បកម្មថ្មី ដែលតម្រូវឲ្យសុំច្បាប់រួមទាំងលក្ខខណ្ឌលម្អិតនានា ដែលចែងក្នុងប្រកាសអនុញ្ញាតនោះ។ ក្នុងករណីរោងចក្រ សិប្បកម្ម ផលិត និង/ឬ ជួសជុលឧបករណ៍មាត្រាសាស្ត្រ ក្រោយពេលបញ្ចប់ការសាងសង់រួចរាល់រោងចក្រ សិប្បកម្មត្រូវមានអាជ្ញាប័ណ្ណផលិត និង/ឬ ជួសជុល មួយទៀត មុននឹងចាប់ផ្តើមប្រតិបត្តិការដំបូង។

**វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ** សំដៅដល់ ការចុះឈ្មោះក្រុមហ៊ុនរោងចក្រ សហគ្រាស សិប្បកម្ម អង្គភាពផ្សេងៗ ក្នុងបញ្ជីមាត្រាសាស្ត្រជាលាយលក្ខណ៍អក្សរដោយមជ្ឈមណ្ឌលមាត្រា-សាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលមានសុពលភាព ៣ (បី) ឆ្នាំ សម្រាប់យកទៅ

ប្រើប្រាស់ ទៅតាមច្បាប់ដែលអាចប្រើបាននិងបញ្ជាក់ថាអង្គភាពសេដ្ឋកិច្ចខាងលើនេះបានធ្វើពាណិជ្ជកម្ម អាជីវកម្ម ឬ សេវាកម្មពាក់ព័ន្ធនឹងផ្នែកមាត្រាសាស្ត្រ។

**អ្នកស្នើសុំ** សំដៅដល់ បុគ្គលដែលចុះហត្ថលេខាលើលិខិតស្នើសុំអនុលោមតាមប្រកាសនេះ។ អ្នកស្នើសុំទាំងអស់មានសេរីភាពក្នុងការជួលភ្នាក់ងារជាភាគីទីបីតាមជម្រើសរបស់ខ្លួនដើម្បីដាក់ និងដំណើរការដាក់ពាក្យស្នើសុំ។

**ប្រការ ៣ :** រាល់ការស្នើសុំអាជ្ញាប័ណ្ណផលិតឧបករណ៍មាត្រាសាស្ត្រ ត្រូវបំពេញបែបបទតាមទម្រង់កំណត់ដោយ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ រាល់ការស្នើសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោមៈ

ក.ពាក្យស្នើសុំ

ខ.ប្រកាសអនុញ្ញាតបង្កើតរោងចក្រ សិប្បកម្ម ឬ ចុះបញ្ជីសិប្បកម្ម

គ.វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ

ឃ.បញ្ជីរាយឈ្មោះឧបករណ៍មាត្រាសាស្ត្រដែលនឹងត្រូវធ្វើការស្នើសុំផលិត

ង.វិញ្ញាបនបត្រអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រដែលត្រូវផលិត

ច.របាយការណ៍វាយតម្លៃរបស់មន្ត្រីបច្ចេកទេស មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដល់ទីកន្លែងរោងចក្រ/សិប្បកម្ម

(អ្នកស្នើសុំត្រូវជូនដំណឹងដល់មន្ត្រីបច្ចេកទេស មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ចុះពិនិត្យអង្កេតស្ថានភាព ទីកន្លែង ផលិត ក្រោយពីបំពេញបែបបទខាងលើរួច)។

**ប្រការ ៤ :** រាល់ការស្នើសុំអាជ្ញាប័ណ្ណជួសជុលឧបករណ៍មាត្រាសាស្ត្រ ត្រូវបំពេញបែបបទតាមទម្រង់កំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។ រាល់ការស្នើសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោមៈ

ក.ពាក្យស្នើសុំ

ខ.ប្រកាសអនុញ្ញាតបង្កើតរោងចក្រ/សិប្បកម្មឬចុះបញ្ជីសិប្បកម្ម(បើមាន)

គ.វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ

ឃ.បញ្ជីរាយឈ្មោះឧបករណ៍មាត្រាសាស្ត្រដែលត្រូវស្នើសុំជួសជុល

ង.របាយការណ៍វាយតម្លៃរបស់មន្ត្រីបច្ចេកទេស មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដល់ទីកន្លែងរោងចក្រ សិប្បកម្ម

(អ្នកស្នើសុំត្រូវជូនដំណឹងដល់មន្ត្រីបច្ចេកទេសមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ចុះពិនិត្យអង្កេតស្ថានភាព ទីកន្លែង ជួសជុលក្រោយពីបំពេញបែបបទខាងលើរួច)។

**ប្រការ ៥ :** អ្នកស្នើសុំត្រូវបំពេញពាក្យស្នើសុំអាជ្ញាប័ណ្ណផលិត និង/ឬ ជួសជុលឧបករណ៍មាត្រាសាស្ត្រដែលអាចទំនាក់ទំនងរកបានដូចខាងក្រោមៈ

ក. នៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ(ម.ម.ជ) នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ខ. នៅសាខា ម.ម.ជ នៃមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានី-ខេត្ត

គ.តាមរយៈ វិបសាយ (Website):www.nmc.mime.gov.kh ឬ

អ៊ីមែល(E-mail): dlegalm.nmc@gmail.com

មាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល។

**ប្រការ ១០ :** អាជ្ញាប័ណ្ណ អាចត្រូវបានព្យួរទុកក្នុងរយៈ ពេលមួយ មិនលើសពីបីខែក្នុងមួយលើកប្រសិនបើៈ

ក. មិនបានប្រតិបត្តិតាមប្រការ ៨ នៃប្រកាសនេះ

ខ. ប្រើប្រាស់អាជ្ញាប័ណ្ណ ឬ អនុវត្តមិនបានត្រឹមត្រូវហើយមិនបានចាត់វិធានការដោះស្រាយ ឬ កែតម្រូវឲ្យទាន់ពេលវេលា តាមការកំណត់របស់មន្ត្រីត្រួតពិនិត្យ ឬមន្ត្រីមានសមត្ថកិច្ចរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

គ. រំលោភទៅនឹងបទប្បញ្ញត្តិណាមួយនៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ប្រកាស ឬបទបញ្ជាបច្ចេកទេសពាក់ព័ន្ធ ។

**ប្រការ ១១ :** អាជ្ញាប័ណ្ណ អាចត្រូវបានដកហូតនៅពេលដែលបានរកឃើញថា អ្នកកាន់អាជ្ញាប័ណ្ណៈ

ក. មិនបានប្រតិបត្តិទៅតាមប្រការ ៩ នៃប្រកាសនេះ

ខ.បានប្រព្រឹត្តកំហុសដូចគ្នាទៅនឹងកំហុសដែលនាំឲ្យមានការព្យួរទុកលើកមុន។

**ប្រការ ១២ :** នៅពេលអាជ្ញាប័ណ្ណត្រូវបានព្យួរទុក ឬដកហូត អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវបញ្ជាក់តាមរូបភាពណាមួយបង្ហាញថាឧបករណ៍មាត្រាសាស្ត្រនោះមានអាជ្ញាប័ណ្ណទេ ហើយត្រូវតែផ្អាកភ្លាមនូវសកម្មភាពផលិត ឬ ជួសជុលឧបករណ៍មាត្រាសាស្ត្រនោះ។

**ប្រការ ១៣ :** ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណមិនបានអនុវត្តតាមប្រការ ១២ ខាងលើ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ មានសិទ្ធិលុបចោលអាជ្ញាប័ណ្ណជាស្វ័យប្រវត្តិ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ចដើម្បីរឹបអូសឧបករណ៍មាត្រាសាស្ត្រដែលបានផលិត ឬ ជួសជុល ក្នុងរយៈពេលព្យួរទុក ឬ ដកហូត ទុកជាសម្បត្តិរដ្ឋ។

**ប្រការ ១៤ :** នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណ មានបំណងឈប់ដំណើរការផលិត និង ជួសជុល ហើយជាមួយគ្នានោះដែរ មានបំណងបោះបង់ចោលអាជ្ញាប័ណ្ណរបស់ខ្លួន អ្នកកាន់អាជ្ញាប័ណ្ណត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីមូលហេតុមកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណមិនបានជូនដំណឹងមកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិទេនោះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវទទួលទោសតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ គ្មានការសងវិញ ទាំងស្រុង ឬចំណែកណាមួយ នៃកម្រៃអាជ្ញាប័ណ្ណដែលបានបង់នោះឡើយ ។ ការបោះបង់ចោល អាជ្ញាប័ណ្ណត្រូវចាត់ទុកថាជាការបញ្ឈប់ដំណើរសេវាកម្មលើការផលិត ឬ ជួសជុលឧបករណ៍មាត្រាសាស្ត្រ ចាប់ពីថ្ងៃចុងក្រោយបង្អស់នៃខែដែលបានទទួលសេចក្តីសម្រេចជាផ្លូវការរបស់មជ្ឈមណ្ឌលមាត្រា-សាស្ត្រជាតិ ។

**ប្រការ ១៥ :** ក្នុងករណីមានការកំណត់គំរូថ្មីមួយ ឬមានការកែប្រែគំរូនៃការចេញអាជ្ញាប័ណ្ណ អ្នកកាន់អាជ្ញាប័ណ្ណដែលមានបំណងអនុវត្តតាមគំរូថ្មី ឬគំរូដែលមានការកែប្រែនោះ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណគំរូថ្មី ។ បន្ទាប់ពីបានដាក់ពាក្យស្នើសុំរួច អ្នកកាន់អាជ្ញាប័ណ្ណអាចបន្តដំណើរការរបស់ខ្លួននៅក្រោមអាជ្ញាប័ណ្ណ និងគំរូចាស់ក្នុងរយៈពេលមួយដែលបានកំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ មិនលើសពីមួយឆ្នាំគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃគំរូថ្មី ។

**ប្រការ ១៦ :** ការផ្ទេរសិទ្ធិកាន់កាប់អាជ្ញាប័ណ្ណផលិត និង ជួសជុលឧបករណ៍មាត្រាសាស្ត្រ អ្នកកាន់កាប់អាជ្ញាប័ណ្ណ និង អ្នកទទួលសិទ្ធិកាន់កាប់បន្តត្រូវមកទំនាក់ទំនងធ្វើការផ្ទេរសិទ្ធិកាន់កាប់អាជ្ញាប័ណ្ណនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ អ្នកទទួលសិទ្ធិថ្មីត្រូវដំណើរការផលិត ឬ ជួសជុលឧបករណ៍មាត្រាសាស្ត្រ ដោយគោរពតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងអាជ្ញាប័ណ្ណ និងកិច្ចព្រមព្រៀងដែលនៅមានសុពលភាពជាធរមាន។

**ប្រការ ១៧ :** ការព្រមាន និង ពិន័យអន្តរការណ៍ដែលមានចែងក្នុងប្រកាសនេះត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យ។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិត្រូវបញ្ជូនសំណុំរឿងទៅតុលាការ។

**ប្រការ ១៨ :** រាល់ប្រកាស និង សេចក្តីសម្រេចទាំងឡាយណា ដែលមានន័យផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៩ :** អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាននីតិកម្ម ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ និង ប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ។

**ប្រការ២០ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**

*កន្លែងទទួល :*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
  "ដើម្បីគោរពជូនជ្រាប"
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- គ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ
- សភាពាណិជ្ជកម្មកម្ពុជា
- គ្រប់សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់នាយកដ្ឋានសេនាធិការក្រសួងឧរថ
- គ្រប់សហគ្រាសសាធារណៈចំណុះក្រសួងឧរថ
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ដូចប្រការ១៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ